## ប្រាក់រង្វាន់ម្តង

ប្រាក់រង្វាន់ម្តង (one-time awards) គឺជាប្រាក់ជំនួយដល់បណ្តាបុគ្គល និងគ្រួសារដែលមានលក្ខណៈជួបតាមសេចក្តីតម្រូវខាងលក្ខណសម្បត្តិនៃកម្មវិធី IFS ហើយដែលមានសេចក្តីត្រូវការតែម្តងដោយគ្មានការរ៉ាប់រងពីប្រភពដទៃណាឡើយ។ សេវាកម្មដែលអាចផ្តល់រង្វាន់ជូនតែម្តង មានដូចជា សេវាកែសម្រួលសំណង់អាគារ, យានយន្ត, ឬបរិក្ខារឯកទេសកម្ម។

## ប្រាក់ជំនួយអាសន្ន

សេវាអាសន្នគឺជាសេវាថែទាំជំនួយដែក្នុងរយៈពេលខ្លីៗម្តងម្កាល, សេវាគ្រប់គ្រងឥរិយាបថ ឬសេវាគិលានុបដ្ឋាយិកិច្ចចំពោះឧប្បត្តិហេតុ, ស្ថានភាព, ឬវិបត្តិរយៈពេលខ្លីដែលកើតឡើងតែម្តងគត់។

អ្នកមានលក្ខណសម្បត្តិទទួលបាននូវការពិចារណាមើលអំពីលទ្ធភាពអនុម័តិការផ្តល់រង្វាន់ ឬប្រាក់ជំនួយអាសន្នម្តង ប្រសិនបើ ៖

- *បច្ចុប្បន្ននេះ អ្នកមិនត្រូវបានទុញ្ញាត ឲ្យទទួលសេវាបម្រើនៃកម្មវិធី IFS ;*
- *សេចក្តីត្រូវការនោះមានលក្ខណៈសំខាន់ដល់សុខភាព និងសុវត្ថិភាពរបស់អ្នក ឬរបស់អ្នកផ្តល់កិច្ចថែទាំរបស់អ្នក ; ហើយប្រសិនបើ*
- *អ្នក និងគ្រួសាររបស់អ្នកគ្មានធនធានណាដទៃទៀត ដើម្បីធ្វើឲ្យស្របតាមសេចក្តីត្រូវការនេះ។*

ក្រសួង *DSHS* មិនប្រកាន់រើសអើងចំពោះជនណាម្នាក់ឡើយ ហើយផ្តល់លទ្ធភាពជូនមនុស្សគ្រប់រូបដើម្បីប្រើប្រាស់កម្មវិធី និងសេវាបម្រើរបស់ក្រសួង ដោយគ្មានការប្រកាន់ពូជសាសន៍, ពណ៌សម្បុរ, ភេទ, សាសនា, គោលជំនឿ, ឋានៈអាពាហ៍ពិពាហ៍, ជាតិកំណើត, ជម្រើសផ្លូវភេទ, អាយុ, ឋានៈអតីតយុទ្ធជន, ឬវត្តមាននៃពិការភាពខាងផ្នែករាងកាយ, វិញ្ញាណ ឬសតិបញ្ញាឡើយ។




**តំបន់ (Region) 1**
1611 W. Indiana Ave.
Spokane, WA 99205-4221
ទូរស័ព្ទ ៖ (509) 329-2900
1 (800) 462-0624

**តំបន់ (Region) 2**
3700 Fruitvale Blvd.
Ste. 200
Yakima, WA 98909-2500
ទូរស័ព្ទ ៖ (509) 225-4620
1 (800) 822-7840

**តំបន់ (Region) 3**
840 N. Broadway
Bldg. A. Suite 100
Everett, WA 98201-1288
ទូរស័ព្ទ ៖ (425) 339-4833
1 (800) 788-2053

**តំបន់ (Region) 4**
1700 E. Cherry St. # 200
Seattle, WA 98122
ទូរស័ព្ទ ៖ (206) 568- 5700
1 (800) 314-3296

**តំបន់ (Region) 5**
1305 Tacoma Ave. S.
Suite 300
Tacoma, WA 98402
ទូរស័ព្ទ ៖ (253) 404-6500
1 (800) 248-0949

**តំបន់ (Region) 6**
Point Plaza East
Bldg. 2, 3rd Floor
6860 Capitol Blvd. SE
Olympia, WA 98504-5315
ទូរស័ព្ទ ៖ (360) 725-4250
1 (800) 339-8227

**សំរាប់ព័ត៌មានពិស្តារបន្ថែម,**
**សូមមើលគេហទំព័ររបស់នាយកដ្ឋាន DDD នៅ ៖**
**www.dshs.wa.gov/ddd**

Washington State
Department of Social
& Health Services

DSHS 22-038(X) CA

Rev. 3/09

Washington State
Department of Social
& Health Services
ADSA Aging & Disability
Services Administration

## នាយកដ្ឋានគ្រប់គ្រងជនពិការពីកំណើត-ក្មេងវ័យ

# កម្មវិធី សេវាបម្រើ ឯកត្តជន និងគ្រួសារ

*ព័ត៌មានស្តីអំពី*
*លក្ខណសម្បត្តិ,*
*លទ្ធភាពប្រើប្រាស់,*
*និងសេវាបម្រើ*

www.dshs.wa.gov/ddd/index.shtml

# គោលសង្ខេបនៃសេវាបម្រើឯកត្តជន និងគ្រួសារ

កម្មវិធីសេវាបម្រើឯកត្តជន និងគ្រួសារ (Individual and Family Services - IFS) គឺជាកម្មវិធីមួយដែលឧបត្ថម្ភដោយប្រាក់ជំនួយរបស់រដ្ឋ ដែលផ្តល់សេវាបម្រើចម្រុះជាច្រើនប្រភេទ ដើម្បីជួយបណ្តាគ្រួសារ ឲ្យអាចរក្សាបាន និងថែលំនឹងឯកភាពគ្រួសារ។

កម្មវិធី IFS រួមញ្ចូលនូវកម្មវិធីឧបត្ថម្ភមុនៗចំនួនបី (សរុបមានកម្មវិធីសាកល្បងបវេណីគ្រួសារ, កាលានុវត្តភាពគ្រួសារ, និងឧបត្ថម្ភគ្រួសារ - Traditional, Opportunity, and the Family Support Pilot) ឲ្យទៅជាកម្មវិធីតែមួយ។

កម្មវិធី IFS គឺជាកម្មវិធីដែលផ្តោតគោលដៅលើការធ្វើសហប្រតិបត្តិជាដៃគូរវាងរដ្ឋ និងបណ្តាគ្រួសារដើម្បី ៖

- *ជួយឧបត្ថម្ភគ្រួសារនានា ដែលមានសមាជិកមានលក្ខណសម្បត្តិទទួលជំនួយ DDD ដែលកំពុងរស់នៅក្នុងផ្ទះរបស់គ្រួសារខ្លួន ;*
- *ផ្តល់សេវាបម្រើជូនគ្រួសារនានាទៅតាមជម្រើសដែលពួកគេចង់បាន ; ហើយនិង*
- *អនុញ្ញាតឲ្យគ្រួសារនានាមានអំណាចគ្រប់គ្រងច្រើនថែមទៀតលើធនធាននានា ដែលមានត្រៀមបម្រុងទុកសំរាប់ពួកគេ។*

## លក្ខណៈវិនិច្ឆ័យលក្ខណសម្បត្តិ IFS

អ្នកមានលក្ខណសម្បត្តិទទួលបាននូវការពិចារណាមើលអំពីលទ្ធភាពអនុម័តិការផ្តល់ជំនួយ IFS ប្រសិនបើ ៖

- *បច្ចុប្បន្ននេះ អ្នកជាអតិថិជនមានលក្ខណសម្បត្តិទទួលជំនួយ DDD ;*
- *អ្នកកំពុងរស់នៅក្នុងផ្ទះគ្រួសាររបស់អ្នក ;*
- *អ្នកមិនចុះឈ្មោះក្នុងកម្មវិធីអនុគ្រោះសេវាបម្រើផ្អែកលើលំនៅដ្ឋាន និងសហគមន៍ DDD (DDD Home and Community Based Services (HCBS) Waiver) ;*
- *អ្នកមានអាយុចាប់ពីបីឆ្នាំឡើងទៅ ; ហើយប្រសិនបើ*
- *អ្នកមិនកំពុងទទួលសេវាបម្រើទីតិជន ឬកុមារនៅតាមផ្ទះ, ឬនៅតាមមន្ទីរចិញ្ចឹមក្មេងកំព្រាមានអាផ្សាប័ណ្ណ។*

## លទ្ធភាពប្រើប្រាស់កម្មវិធី IFS

អ្នកអាចទាក់ទងនាយកគ្រប់គ្រងធនធានសំណុំរឿង DDD របស់អ្នក ដើម្បីស្នើសុំសេវាបម្រើនៃកម្មវិធី IFS ។ អ្នកនឹងទទួលបាននូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីអំពីការអនុម័តិ ឬការបដិសេធ រួមជាមួយនឹងលិខិតជូនដំណឹងស្តីអំពីសិទ្ធិស្នើសុំសវនាការរដ្ឋបាលរបស់អ្នក។

## បញ្ជីស្នើសុំកម្មវិធី IFS

បញ្ជីស្នើសុំកម្មវិធី IFS មានរួមបញ្ចូលនូវឈ្មោះបុគ្គលទាំងឡាយដែលកំពុងរស់នៅជាមួយគ្រួសាររបស់ពួកគេ ហើយដែលបានស្នើសុំសេវាបម្រើនៃកម្មវិធី IFS ។ បើប្រាក់ជំនួយគ្មានបម្រុងនៅក្នុងខណៈពេលនៃការស្នើសុំនេះទេ, នោះឈ្មោះបុគ្គលដែលមានលក្ខណសម្បត្តិទាំងអស់នឹងត្រូវគេចុះក្នុងបញ្ជីរង់ចាំ ដោយរាប់ចាប់តាំងពីថ្ងៃស្នើសុំជំនួយរបស់ពួកគេ។

## ការត្រៀមបម្រុងប្រាក់ជំនួយ IFS ប្រចាំឆ្នាំ

ទម្រង់ការវាយតម្លៃ DDD ត្រូវបានរចនាឡើង ដើម្បីវាស់ស្ទង់មើលអំពីការឧបត្ថម្ភសេចក្តីត្រូវនានារបស់បណ្តាមនុស្ស ដែលមានពិការភាពពីកំណើត-ក្មេងវ័យ ហើយត្រូវគេប្រើប្រាស់ ដើម្បីកំណត់មើលកម្រិតសេចក្តីត្រូវការរបស់អ្នក។ ការត្រៀមបម្រុងប្រាក់ជំនួយ IFS ប្រចាំឆ្នាំសរុបមាន ៖

- *កម្រិតទី 1 រហូតដល់ទៅ $2,000*
- *កម្រិតទី 2 រហូតដល់ទៅ $3,000*
- *កម្រិតទី 3 រហូតដល់ទៅ $4,000*
- *កម្រិតទី 4 រហូតដល់ទៅ $6,000*

## សេវាកម្មដែលមានបម្រើការ

### *ការជួយមើលថែទាំជំនួសដៃជាបណ្តោះអាសន្នម្តងម្កាល*

ការជួយមើលជំនួសដៃរយៈពេលខ្លីៗម្តងម្កាលក្នុងការផ្តល់សេវាថែទាំបុគ្គលដែលជាសមាជិកនៃគ្រួសារណាមួយ ដែលកំពុងទទួលជំនួយកម្មវិធី IFS ។

### *ថ្លៃជំពាក់វេជ្ជសាស្ត្រសេសសល់ដែលគ្មានការរ៉ាប់រងពីសេវាកម្មដទៃណាមួយ*

ថ្លៃជាប់ជំពាក់វេជ្ជសាស្ត្រដែលនៅគរសេសសល់ ក្រោយពេលដែលកម្មវិធីមេឌីខេដ (Medicaid) ឬក្រុមហ៊ុនធានារ៉ាប់រងវេជ្ជសាស្ត្រឯកជនបានបង់សងចំណែក ដែលពួកគេត្រូវបង់សងរួចស្រេចបាច់អស់ហើយ ដោយសារអ្នកបានចាយវាយលើសកម្រិត, ឬមួយក៏ថ្លៃចំណាយលើវេជ្ជសាស្ត្រ ដែលអ្នកបានធ្វើឡើងក្នុងគ្រាដែលអ្នកមិនទាន់មានការធានារ៉ាប់រងវេជ្ជសាស្ត្រនៅឡើយ។

### *វិធីព្យាបាលស្មេរ៉ាប់ពីស៍*

វិធីព្យាបាល*ស្មេរ៉ាប់ពីស៍* (therapies) ដែលត្រូវបានរ៉ាប់រងដោយកម្មវិធី IFS មាន ៖

- *ការព្យាបាលស្មេរ៉ាប់ពីខាងផ្នែករាងកាយ*
- *ការព្យាបាលស្មេរ៉ាប់ពីខាងផ្នែកអាជីវកម្ម*
- *ការព្យាបាលស្មេរ៉ាប់ពីខាងផ្នែនិយាយស្តី, ស្តាប់, និងភាសា*

### *ការកែសម្រួលសំណង់អាគារ និងយានយន្ត*

ការបន្សាំខ្លួនទៅនឹងផ្ទះសម្បែង និងយានយន្តរបស់មនុស្សណាម្នាក់ដើម្បីធានាដល់សុខភាព, សុខុមាលភាព, និងសុវត្ថិភាពរបស់អតិថិជននិងអ្នកផ្តល់កិច្ចថែទាំ; ឬការធ្វើឲ្យអតិថិជន, ដែលត្រូវការបរិស្ថានមានកម្រិតដោយប្រការណាមួយ, អាចអនុវត្តដំណើរការរស់នៅប្រចាំថ្ងៃបានដោយរលូនដោយមិនចាំបាច់ពឹងផ្អែកលើអ្នកដទៃនៅក្នុងផ្ទះ និងសហគមន៍របស់ពួកគេ។

### *បរិក្ខារ និងឧបករណ៍*

បរិក្ខារ និងឧបករណ៍ចាំបាច់ខាងផ្នែកវេជ្ជសាស្ត្រ ដែលត្រូវបានរចនាឡើង ដើម្បីជួយបណ្តាមនុស្ស ឲ្យអាចបង្កើន ឬរក្សាបាននូវសមត្ថភាពរបស់ពួកគេ ហើយនិងដើម្បីឲ្យអាចអនុវត្តដំណើររស់នៅប្រចាំថ្ងៃរបស់ពួកគេដោយរលូន។

### *អាហារូបត្ថម្ភ និងសំលៀកបំពាក់ឯកទេសកម្ម*

អាហារបំប៉នតាមរូបមន្ត ឬតាមលក្ខណៈពិសេសទៅតាមសេចក្តីណែនាំជាលាយលក្ខណ៍អក្សរ ដែលបានធ្វើឡើងដោយអ្នកប្រកបវិជ្ជាជីវៈមានគុណសម្បត្តិ និងសមស្របណាម្នាក់ ហើយនៅពេលណាអាហារូបត្ថម្ភប្រភេទនេះផ្តល់រសកាឡូរី 50 ភាគរយ ដើម្បីចិញ្ចឹមសពាង្គកាយរបស់ជនរូបនោះ។

សំលៀកបំពាក់គ្មានល័ក្ខខ័ណ្ឌកម្រិត ដែលបានរចនាឡើងដើម្បីបន្សាំទៅនឹងស្ថានភាពជាក់ស្តែងនៃពិការភាព, សំលៀកបំពាក់សមស្រប ឬស្បែកជើងឯកទេសកម្មពិសេស ដែលបានរចនាទៅតាមបែបបទនៃអនុសាសន៍លាយលក្ខណ៍អក្សរ ដែលបានណែនាំដោយអ្នកប្រកបវិជ្ជាជីវៈជំនាញមានគុណសម្បត្តិណាម្នាក់។

### *ការបង់ប្រាក់សហការ (co-pays) សំរាប់ថ្លៃសេវាវេជ្ជសាស្ត្រ និងសេវាព្យាបាលស្មេរ៉ាប់ពីស៍*

ប្រាក់ក្នុងចំនួនថេរដែលអ្នកជាវផែនការវេជ្ជសាស្ត្រត្រូវតែបង់ ដើម្បីអាចប្រើប្រាស់សេវាវេជ្ជសាស្ត្រ ឬសេវាព្យាបាល*ស្មេរ៉ាប់ពីស៍*នានា ដែលត្រូវបានរ៉ាប់រងដោយផែនការដែលពួកគេជាវនោះ។

### *ការធ្វើដំណើរដឹកជញ្ជូន*

ការផ្តល់ប្រាក់សំណងដល់អ្នកផ្តល់កិច្ចថែទាំវិញ នៅពេលណាការធ្វើដំណើរដឹកជញ្ជូនត្រូវបានតម្រូវ ដើម្បីអាចចេញចូលប្រើប្រាស់សេវា IFS ទៅបាន។

### *ការបណ្តុះបណ្តាល និងការផ្តល់ឱវាទ*

មានការផ្តល់ជំនួយឯកទេសជំនាញ ជូនដល់បណ្តាគ្រួសារនានា ដើម្បីឲ្យអាចបំពេញសេចក្តីត្រូវការជាក់លាក់របស់បុគ្គល ឲ្យបានគាប់ប្រសើរឡើង។

### *ការគ្រប់គ្រងការឥរិយាបថ*

ការអភិវឌ្ឍន៍ និងការអនុវត្តន៍តាមកម្មវិធីនានា ដែលប្រើបច្ចេកទេសឥរិយាបថជាវិជ្ជមាន ដើម្បីឧបត្ថម្ភបណ្តាមនុស្ស ដែលមានការប្រឈមនឹងឥរិយាបថ។

### *ការអប់រំឪពុកម្តាយ/បងប្អូន*

ការបណ្តុះបណ្តាលក្នុងថ្នាក់រៀនលើប្រធានបទដែលពាក់ព័ន្ធដល់ឪពុកម្តាយ និងបងប្អូន ដែលមានសមាជិកគ្រួសារមានពិការភាពពីកំណើត-ក្មេងវ័យ។

### *កាលានុវត្តភាពកែកម្សាន្ត*

សកម្មភាពលម្ហែនានាដែលអាចមានបម្រើការដល់បណ្តាអតិថិជនដែលមានលក្ខណសម្បត្តិ ដូចជាការបោះជុំរុំរដូវក្តៅ, សកម្មភាព YMCA, ការធ្វើដំណើរកម្សាន្តនៅពេលថ្ងៃ, សមាជិកភាពក្នុងក្រុមពលរដ្ឋ, ក្លឹប, ថ្នាក់សិប្បកម្ម, សកម្មភាពកីឡា, ឬសកម្មភាពកែកម្សាន្តធម្មតាដទៃៗទៀត ដែលមានបម្រើការក្នុងសហគមន៍។